00648747

E51/5/1

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសង |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់ដាក់ចម្លើយតបទៅនឹងអញ្ញត្រកម្មបឋមរបស់ជនជាប់ចោទ

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:

លោកស្រី ជា លាង

លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រមJean-Marc LAVERGNE

ចៅក្រម ធូ មណី

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:

ពេជ អង្គ

Elisabeth SIMONNEAU FORT

ជនជាប់ចោទ:

នួន ជា

អៀង សារី

អៀង ធីរិទ្ធ

ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor Koppe

លោក អាង ឧត្តម

លោក Michael G.KARNAVAS

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 01 / 03 / 2011
ម៉ោង (Time/Heure): 14 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

លោក ស សូវាន

លោក Jacques VERGÈS

លោក Phillipe GRECIANO

## I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាសូមស្នើថា កាលបរិច្ឆេទកំណត់សម្រាប់ដាក់ចម្លើយតបទៅនឹងអញ្ញត្រកម្មបឋមរបស់ជនជាប់ចោទ ពន្យារពេលដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ ហើយចំនួនទំព័រកំណត់សម្រាប់ចម្លើយតបរួមនេះ បង្កើនឡើងដល់ចំនួន៤០ទំព័រ ជាប្រយោជន៍ដើម្បីឱ្យសហព្រះរាជអាជ្ញាអាចនឹងឆ្លើយតបបានយ៉ាងត្រឹមត្រូវទៅនឹងអញ្ញត្រកម្មបឋមនោះ។

## II. សាវតារ និងដោះឈោះស្រាយដែលស្វែងរក

២. នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ បង្គាប់ឱ្យភាគីនីមួយៗដាក់អញ្ញត្រកម្មបឋម យ៉ាងដូច្នេះតាមរយៈការដាក់តែមួយដែលមានចំនួន១៥ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង និងចំនួន៣០ទំព័រ ជាភាសាខ្មែរ ដោយមានគោលសេចក្តីនៃអញ្ញត្រកម្មបឋមរបស់ភាគីនីមួយៗនោះ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១១[1]។ អនុស្សរណៈនេះកំណត់កាលបរិច្ឆេទថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ សម្រាប់សហព្រះរាជអាជ្ញាឆ្លើយតប ដោយមានកម្រិតចំនួនត្រឹម៥ទំព័រ សម្រាប់ចម្លើយតបនីមួយៗ ដែលជាដំបូងត្រូវដាក់ជាភាសាអង់គ្លេស ឬជាភាសាបារាំង ក្នុងករណីចាំបាច់(ជាសរុបចំនួន២០ទំព័រ)។

៣. មុនពេលចេញអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង នួន ជា បានដាក់អញ្ញត្រកម្មបឋមដែលមាន(ចំនួន១៥ទំព័រជាភាសាអង់គ្លេស និងចំនួន៣១ទំព័រជាភាសាខ្មែរ) នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១[2] និងបន្ទាប់មកទៀតគឺដាក់អញ្ញត្រកម្មបន្ថែមមាន(ចំនួន១១ទំព័រជាភាសាអង់គ្លេស និងចំនួន១៩ទំព័រជាភាសាខ្មែរ) នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១[3]។ នៅថ្ងៃទី១៤ និង១៥ ខែកុម្ភៈ ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានទទួល ១) អញ្ញត្រកម្មបឋមរបស់ អៀង ធីរិទ្ធ (១៣ទំព័រ ជាភាសាអង់គ្លេស និងចំនួន២០ទំព័រជាភាសាខ្មែរ)[4], ២) អញ្ញត្រកម្មបឋមចំនួនពីររបស់ អៀង សារី (សរុបចំនួន១០ទំព័រជាភាសាអង់គ្លេស និងចំនួន១៧ទំព័រជាភាសាខ្មែរ)[5] និង ៣) អញ្ញត្រកម្មបឋម

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ "ការជូនដំណឹងរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងនីតិវិធីដែលត្រូវបានធ្វើការកែប្រែសម្រាប់ដាក់អញ្ញត្រកម្ម និងការបញ្ជាក់អំពីកាលបរិច្ឆេទសម្រាប់ការឆ្លើយតប", ថ្ងៃទី១៤ កុម្ភៈ ២០១១ (ដាក់នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១), E51 ។

[2] អញ្ញត្រកម្មបឋមទាក់ទិននឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង, ៨ កុម្ភៈ ២០១១, E36 ។

[3] អញ្ញត្រកម្មបឋមទាក់ទិននឹងនីត្យានុកូលភាពវិធានផ្ទៃក្នុង និងអានុភាពដីកាអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ មករា ២០១១, ១១ កុម្ភ ២០១១, E42 ។

[4] អញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ, ១៤ កុម្ភៈ ២០១១, E44 ។

[5] អញ្ញត្រកម្មបឋមរបស់ អៀង សារី អនុលោមតាមវិធាន៨៩ (អាជ្ញាយុកាលលើអំពើបំពារបំពានធ្ងន់ធ្ងរ), ១៤ កុម្ភៈ ២០១១, E43 ។

ចំនួនពីររបស់ ខៀវ សំផន (ចំនួន២៥ទំព័រជាភាសាបារាំង និងចំនួន៣៣ទំព័រជាភាសាខ្មែរ[6]។ នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១ អៀង សារី បានព្យាយាមដាក់ជាមុននូវច្បាប់ចម្លងនៃអញ្ញត្រកម្មបឋមជាភាសាអង់គ្លេសដែលមានចំនួន១០១ទំព័រ[7]។

៤. នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ ដោយបានបញ្ជាក់ថា នួន ជា ដាក់អញ្ញត្រកម្មបឋមរបស់ខ្លួនឡើងវិញ ក្នុងចំនួន១៥ទំព័រ តាមលក្ខខណ្ឌកំណត់ (ភាសាអង់គ្លេស) ដោយបានទទួលយកការដាក់ឯកសាររបស់ ខៀវ សំផន ចំនួន២ ដោយយោងដូចការរៀបរាប់ខាងលើ និងបានអនុញ្ញាតឱ្យ អៀង សារី បន្ថែមចំនួនទំព័រកំណត់ដល់(២៥ទំព័រជាភាសាអង់គ្លេស/បារាំង និងចំនួន៥០ទំព័រជាភាសាខ្មែរ) ដោយផុតកំណត់ត្រឹមថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១[8]។

៥. កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយដែលអនុញ្ញាត៖ ១) ឱ្យ អៀង សារី នូវពេលវេលាបន្ថែម សម្រាប់ដាក់អញ្ញត្រកម្មបឋមរបស់ខ្លួន នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ ២) នួន ជា នូវចំនួនទំព័របន្ថែមរហូតដល់៣៥ទំព័រ ដែលត្រូវដល់ពេលកំណត់ដាក់នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ និង៣) បដិសេធលើសំណើរបស់ ខៀវ សំផន ដោយមិនឱ្យបន្ថែមចំនួនទំព័រ លើសពីចំនួនដែលបានយល់ព្រមរួចកាលពីមុន[9]។ នៅថ្ងៃទី២៨ ខែកុម្ភៈ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាមួយ ដោយបានបញ្ជាក់កាលបរិច្ឆេទនៅថ្ងៃទី២៨ ខែកុម្ភៈសម្រាប់ អៀង សារី ប៉ុន្តែបានបញ្ជាក់កម្រិតទំព័រត្រឹមចំនួន៣៥ទំព័រជាភាសាអង់គ្លេស និងចំនួន៥០ទំព័រជាភាសាខ្មែរ។

៦. សហព្រះរាជអាជ្ញាកត់សំគាល់អំពីការខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះ ដើម្បីធានាចំពោះប្រសិទ្ធភាពនៃដំណើរការនីតិវិធីទាំងនេះ ហើយនឹងបន្តយកអស់លទ្ធភាពរបស់ខ្លួន ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការងារនេះ។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ដោយយល់ឃើញថាចំនួនទំព័រកំណត់ និងការបន្ថែមពេលវេលាកំណត់ ដែលបានអនុញ្ញាតឱ្យ នួន ជា, អៀង សារី, និង ខៀវ សំផន និងសំណើដាក់អញ្ញត្រកម្មបឋមមានចំនួនច្រើនដែលបានដាក់ គឺមិនអាចផ្តល់ជាចម្លើយតបរួមដ៏ពោរពេញដោយអត្ថន័យ នៅត្រឹមថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ បានទេ និងនៅក្នុងរង្វង់ចំនួនទំព័រកំណត់ពីដើមដំបូងចំនួន២០ទំព័របាននោះទេ។ សហព្រះរាជអាជ្ញា សូមស្នើដោយគោរពថា ពេលវេលាកំណត់សម្រាប់ការដាក់ចម្លើយតបរួមរបស់ខ្លួន ទៅនឹងអញ្ញត្រកម្ម

---

[6] Exceptions Préliminaires Portant Sur la Competence, 14 February 2011, E46; Exceptions Préliminaires Portant Sur l'extinction de l'action Publique (Crimes Nationaux), 14 February 2011, E47។

[7] លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី, ២២ កុម្ភៈ ២០១១, E51/1/1.1.2 ។

[8] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "អញ្ញត្រកម្មបឋម", ១៨ កុម្ភៈ ២០១១, E51/1 ។

[9] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "អញ្ញត្រកម្មបឋម", ២២ កុម្ភៈ ២០១១ ។

បឋម គួរបានពន្យារពេលបន្ថែមរហូតដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ ហើយចំនួនទំព័រកំណត់សម្រាប់ការឆ្លើយតបគួរបានបន្ថែមដល់ចំនួន៤០ទំព័រ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |